# យន្តការដោះស្រាយបញ្ហាទីផ្សារបន្លែនៅកម្ពុជាៈ
# ទ្រឹស្តី និង អនុវត្តន៍

បណ្ឌិត ឆេង វណ្ណារិទ្ធ
ប្រធានស្តីទីវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

សេចក្តីផ្តើម
១.ចំណោទបញ្ហាជាមូលដ្ឋានគ្រឹះប្រាំ
២.ដំណោះស្រាយ
២-១ ការអនុវត្ត"កត្តាសម្រេចនៃការផ្គត់ផ្គង់"
២-២ តួនាទីអន្តរការី
សន្និដ្ឋាន
ឯកសារយោង

## សេចក្តីផ្តើម

នៅក្នុងអត្ថបទ "បញ្ហា និង ដំណោះស្រាយ ទីផ្សារបន្លែនៅកម្ពុជា" ដែលបានចុះផ្សាយក្នុងអត្ថបទស្រាវជ្រាវរបស់មន្ត្រីវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា ក្នុងខែកុម្ភៈ ឆ្នាំ២០១៩ បានបង្ហាញពីបរិមាណបន្លែដែលផលិតដោយកសិករក្នុងស្រុក នៅមិនទាន់គ្រប់គ្រាន់តាមតម្រូវការទីផ្សាររបស់ខ្លួននៅឡើយ ដែលជាហេតុឱ្យមានការនាំចូលបន្លែជាច្រើនដើម្បីបំពេញតម្រូវការក្នុងស្រុកពីប្រទេសជិតខាងច្រើន។ ប្រសិនបើស្ថានភាពនៃការផលិតបន្លែក្នុងស្រុកនឹងស្ថិតក្នុងសភាពដូចនេះជាបន្តទៀត នោះប្រទេសកម្ពុជានឹងបន្តនាំចូលបន្លែកាន់តែច្រើនថែមទៀតពីមួយឆ្នាំទៅមួយឆ្នាំ ពីប្រទេសថៃនិងវៀតណាម។ ក្នុងអត្ថបទដដែលនោះក៏បានបង្ហាញនូវវិធីដោះស្រាយតាមរយៈទ្រឹស្តីទាក់ទងនឹង "កត្តាសម្រេចនៃការផ្គត់ផ្គង់" ("determinants of supply") ដែលក្នុងនោះរួមមាន៖ ១-ថ្លៃលើធនធាន, ២-បច្ចេកវិទ្យា, ៣-ពន្ធ និងការឧបត្ថម្ភធន, ៤-ថ្លៃលើទំនិញដទៃ, ៥-ក្តីរំពឹងចាំ, ៦-ចំនួនផលិតករដែលកត្តាទាំងអស់នេះអាចមានឥទ្ធិពលទៅលើបរិមាណផ្គត់ផ្គង់បន្លែនៅលើទីផ្សារ។

ជាបន្តទៀតនៅក្នុងអត្ថបទ "យន្តការដោះស្រាយបញ្ហាទីផ្សារបន្លែនៅកម្ពុជាៈទ្រឹស្តី និង អនុវត្តន៍" នេះ យើងនឹងបង្ហាញនូវយន្តការដែលអាចជួយឱ្យមានសមតារវាងតម្រូវការនិងការផ្គត់ផ្គង់បន្លែនៅលើទីផ្សារក្នុងស្រុក មានន័យថា បន្លែនឹងត្រូវបានផលិតដោយអនុលោមតាមការប្រើប្រាស់ ឬ ការប្រើប្រាស់ត្រូវទៅតាមការផលិតដោយមិនលើសនិងមិនខ្វះ។

## ១.	ចំណោទបញ្ហាជាមូលដ្ឋានគ្រឹះប្រាំ

ជាបឋមត្រូវយល់ថា គ្រប់ប្រព័ន្ធសេដ្ឋកិច្ចទាំងឡាយ ត្រូវរកចម្លើយលើសំណួរជាមូលដ្ឋានគ្រឹះ ប្រាំ គឺ៖ ១-តើគប្បីផលិតចំនួនប៉ុន្មាន?, ២-តើរបស់អ្វីគប្បីផលិត?, ៣- តើផលិផលនោះគប្បីផលិតបែបណា?, ៤-តើអ្នកណាទទួលផលិតផលនោះ? និង ៥-តើប្រព័ន្ធផលិតកម្មនេះអាចសម្របសម្រួលតាមតម្រូវការ ឬ ការផ្គត់ផ្គង់ធនធាន ក៏ដូចជា ការប្រែប្រួលបច្ចេកវិទ្យាដែរឬទេ?។

តាមការវិភាគស្ថានភាពទីផ្សារបន្លែនៅក្នុងស្រុក យើងឃើញថា៖"បន្លែមួយចំនួនដែលផលិតដោយកសិករក្នុងស្រុក គឺគ្មានអ្នកទិញ ពោលគឺ ផលិតផលលើស ចំណែកឯ បន្លែមួយចំនួនទៀត គឺត្រូវបាននាំចូលពីទីផ្សារខាងក្រៅ ពោលគឺ ផលិតផលក្នុងស្រុកមិនគ្រប់គ្រាន់។

ដូច្នេះយើងអាចអះអាងបានថា នាពេលបច្ចុប្បន្ននេះ សេដ្ឋកិច្ចរបស់យើងទាក់ទងនឹងទីផ្សារបន្លែ គឺមិនទាន់ឆ្លើយតបបានត្រឹមត្រូវលើសំណួរជាមូលដ្ឋានគ្រឹះទាំងប្រាំ(five fundamental questions)ខាងលើនៅឡើយទេ។ តើត្រូវដោះស្រាយបែបណា?

## ២.	ដំណោះស្រាយ

យើងឃើញហើយថា ទីផ្សារបន្លែក្នុងស្រុកមានបញ្ហាពីរគឺ៖ ទីមួយ- ប្រភេទបន្លែខ្លះនិងនៅកន្លែងខ្លះគឺមានផលិតផលលើស ហើយនៅសល់ដោយគ្មានអ្នកទិញ ដោយការផ្គត់ផ្គង់លើស និងទីពីរ- ប្រភេទបន្លែខ្លះនិងនៅកន្លែងខ្លះ មានការផលិតផលខ្វះ ជាហេតុឱ្យមានការនាំចូលពីខាងក្រៅ ដោយការផ្គត់ផ្គង់មិនគ្រប់គ្រាន់។

យើងអាចដោះស្រាយបញ្ហាទាំងនេះ ដោយអនុវត្តតាមរយៈទ្រឹស្តី(សូមមើលៈ រូប៣. "ការប្រែប្រួលក្នុងការផ្គត់ផ្គង់" នៅក្នុងអត្ថបទស្រាវជ្រាវរបស់មន្ត្រីវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជាក្នុងខែកុម្ភៈឆ្នាំ២០១៩)កត្តាមួយចំនួននៃ"កត្តាសម្រេចនៃការផ្គត់ផ្គង់" ("determinants of supply")ដូចខាងក្រោម៖

### ២.១	ការអនុវត្ត"កត្តាសម្រេចនៃការផ្គត់ផ្គង់"

### ក-ថ្លៃលើធនធាន

ទំនិញដែលកសិករយកមកប្រើប្រាស់ជាវត្ថុធាតុដើមសម្រាប់ការដាំដុះបន្លែ ដូចជា ជី ថ្នាំកសិកម្ម ប្រេងឥន្ធនៈ ។ល។ គឺមានថ្លៃខ្ពស់ ធៀបទៅនឹងថ្លៃវត្ថុធាតុដើមនៅក្រៅប្រទេស ដែលជាហេតុឱ្យបន្លែរបស់ប្រជាកសិករខ្មែរបាត់បង់នូវលទ្ធភាពប្រកួតប្រជែង នៅលើទីផ្សារក្នុងស្រុក។ ដូច្នេះដើម្បីកាត់បន្ថយថ្លៃដើម គឺត្រូវប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក ដោយការបង្កើតរោងចក្រផលិតជីនិងថ្នាំកសិកម្ម ក្រោមការវិនិយោគ ឬផ្តល់ហិរញ្ញប្បទាន ពីរដ្ឋាភិបាល។

### ខ-បច្ចេកវិទ្យា

នាពេលបច្ចុប្បន្ននេះកសិករខ្មែរភាគច្រើនដែលដាំបន្លែ គឺធ្វើទៅតាមបែបកសិកម្មយថាផល គ្មានប្រព័ន្ធធារាសាស្ត្រគ្រប់គ្រាន់តាមបច្ចេកទេស គ្មានសម្ភារៈនិងបរិក្ខារសម្រាប់បម្រើការដាំដុះបន្លែគ្រប់គ្រាន់

ឬគ្មានសមត្ថភាពប្រើប្រាស់សម្ភារៈនិងបរិក្ខារទំនើប ការប្រើប្រាស់ដី ពូជ ជី ថ្នាំ គឺមិនត្រឹមត្រូវទៅតាមបទដ្ឋានបច្ចេកទេស ។ល។និង។ល។ ដែលជាហេតុឱ្យទិន្នផលទាប ធ្វើឱ្យថ្លៃដើមផលិតកម្មខ្ពស់។ ទាំងអស់នេះហើយដែលការដាំបន្លែដោយកសិករខ្មែរនៅក្នុងស្រុកដើម្បីផ្គត់ផ្គង់នៅលើទីផ្សារក្នុងស្រុកគឺមិនអាចលក់បានតាមថ្លៃទីផ្សារប្រកួតប្រជែងជាមួយនឹងបន្លែនាំចូលពីខាងក្រៅ ហើយតម្រូវឱ្យប្រទេសកម្ពុជានាំចូលពីប្រទេសវៀតណាម និង ថៃ ប្រមាណជា១៤ ម៉ឺនតោនក្នុង១ឆ្នាំៗដោយចំណាយសាច់ប្រាក់ទៅក្រៅប្រទេសប្រមាណជា២០០លានដុល្លារក្នុង១ឆ្នាំៗ(សូមមើលៈ*http://kleykley.sabay.com.kh/article/1013701* )។

ដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ រដ្ឋាភិបាលគួរតែជំរុញការរៀបចំប្រព័ន្ធស្រោចស្រពត្រឹមត្រូវតាមបច្ចេកទេសស្តង់ដារ និងស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញចុះទៅដល់ទីកន្លែងដើម្បីបណ្តុះបណ្តាលប្រជាកសិករ អំពីបច្ចេកទេសប្រើប្រាស់ដី ទឹក ជី ថ្នាំកសិកម្ម ។ល។និង។ល។ត្រឹមត្រូវតាមបច្ចេកទេសកសិកម្មដើម្បីប្រើប្រាស់ធនធានសេដ្ឋកិច្ចឱ្យមានប្រសិទ្ធភាព បង្កើនទិន្នផល កាត់បន្ថយថ្លៃដើមផលិតកម្ម ធ្វើឱ្យកើនឡើងទាំងបរិមាណនិងសមត្ថភាពប្រកួតប្រជែងនៃបន្លែផលិតក្នុងស្រុក ហើយឈានដល់ម្ចាស់ការនៅលើទីផ្សារបន្លែក្នុងស្រុកដោយខ្លួនឯង។ បន្ថែមពីលើនេះ រដ្ឋាភិបាលក៏ត្រូវបង្រៀនបច្ចេកទេសដល់កសិករដាំបន្លែខ្មែរទាំងអស់ឱ្យចេះកែច្នៃ ខ្ចប់ វេច ផលិតផលបន្លែ ដើម្បីបង្កើនតម្លៃបន្ថែមក្នុងស្រុកនិងឈានដល់ការនាំចេញទៅក្រៅប្រទេសតាមស្តង់ដារ។

### គ- ការឧបត្ថម្ភធន

កសិករខ្មែរដាំបន្លែភាគច្រើនមិនមានទុនគ្រប់គ្រាន់ដើម្បី ពង្រីកផ្ទៃដីដាំដុះ គ្មានលទ្ធភាពទិញសម្ភារៈ បរិក្ខារ បច្ចេកវិទ្យាទំនើប សម្រាប់ប្រើប្រាស់ក្នុងការដាំបន្លែរបស់ខ្លួនឡើយ ស្របពេលដែលអត្រាការប្រាក់កម្ចីធនាគារមានជាមធ្យម១,៥%ក្នុង១ខែ ដែលកម្រិតនេះ គឺខ្ពស់ សម្រាប់វិស័យកសិកម្ម។ ដូច្នេះដើម្បីទ្រទ្រង់ការផ្គត់ផ្គង់បន្លែផលិតដោយកសិករខ្មែរក្នុងស្រុក សម្រាប់បំពេញតម្រូវការទីផ្សារ នោះរដ្ឋាភិបាលគួរឧបត្ថម្ភធន ឬ ឥណទាន ក្នុងកម្រិតអត្រាការប្រាក់ទាប ដើម្បីប្រជាកសិករដាំបន្លែមានទុនគ្រប់គ្រាន់សម្រាប់បំពេញសេចក្តីត្រូវការក្នុងដំណើរការផ្គត់ផ្គង់បន្លែរបស់ខ្លួននៅលើទីផ្សារក្នុងស្រុក។

### ឃ- ចំនួនផលិតករ

កសិករមានចំនួនតិចតួចផលិតបន្លែផ្គត់ផ្គង់ក្នុងស្រុកក៏ជាកត្តាសំខាន់មួយ ដែលតម្រូវឱ្យប្រទេសកម្ពុជានាំចូលបន្លែពីប្រទេសវៀតណាម និង ថៃ ប្រមាណជា២០០តោន ទៅ ៤០០តោន ក្នុងមួយថ្ងៃៗជាមួយតម្លៃទឹកប្រាក់ពី១៥០-២០០លានដុល្លាក្នុងមួយឆ្នាំ( សូមមើលៈ*https://www.dap-news.com/2018/07/04/*)។ ដូច្នេះរដ្ឋាភិបាលត្រូវមានគោលនយោបាយដើម្បីទាក់ទាញឱ្យមានចំនួនផលិតករដាំបន្លែច្រើនថែមទៀត ដើម្បីផ្គត់ផ្គង់នៅលើទីផ្សារបំពេញតម្រូវការក្នុងស្រុក។ ជាការពិតណាស់ថា ក្នុងរបបសេដ្ឋកិច្ចទីផ្សារសេរី ផលិតករជាឯកជន គឺពួកគេនឹងផលិតអ្វីដែលផ្តល់នូវផលចំណេញច្រើន តែបើមិនចំណេញគឺពួកគេនឹងមិនផលិតឡើយ។

ជាបន្តទៀតតើត្រូវធ្វើបែបណាដើម្បីទាក់ទាញកសិករខ្មែរ ឱ្យងាកទៅប្រកបរបរដាំបន្លែដើម្បីផ្គត់ផ្គង់នៅលើទីផ្សារក្នុងស្រុក?។ ដូចបានបញ្ជាក់ពីខាងដើមស្ថានភាពទីផ្សារបន្លែនៅប្រទេសកម្ពុជា ក្រៅពីការនាំបន្លែចូលពីក្រៅប្រទេស និង ថ្លៃបន្លែឡើងចុះគ្មានភាពច្បាស់លាស់ ក៏មានករណី ដែលបន្លែខ្លះនិងនៅកន្លែងខ្លះនៃប្រទេសកម្ពុជា មានផលិតផលលើស ហើយនៅសល់ដោយគ្មានអ្នកទិញ ដោយការផ្គត់ផ្គង់លើស។ កត្តានេះហើយដែលជាឧបសគ្គមិនលើកទឹកចិត្តឱ្យកសិករខ្មែរដាំបន្លែដើម្បីផ្គត់ផ្គង់នៅលើទីផ្សារ។

បញ្ហានេះកើតឡើងដោយមូលហេតុ កសិករជាអ្នកដាំបន្លែ មិនបានដឹងអំពីសំណួរជាមូលដ្ឋានគ្រឹះប្រាំ(five fundamental questions)ពីខាងដើម គឺ ១-តើគប្បីផលិតចំនួនប៉ុន្មាន, ២-តើរបស់អ្វីគប្បីផលិត?, ៣-តើផលិផលនោះគប្បីផលិតបែបណា?, ៤-តើអ្នកណាទទួលផលិតផលនោះ? និង ៥-តើប្រព័ន្ធផលិតកម្មនេះអាចសម្របសម្រួលតាម តម្រូវការ ឬ ការផ្គត់ផ្គង់ធនធាន ក៏ដូចជា ការប្រែប្រួលបច្ចេកវិទ្យាដែរឬទេ?។

តើត្រូវដោះស្រាយដោយវិធីណា?

## ២.២ តួនាទីអន្តរការី

បញ្ហាខាងលើនេះ យើងអាចនិយាយយ៉ាងខ្លីថា បន្លែដែលដាំដុះនៅក្នុងស្រុកគឺ "**គ្មានទីផ្សារ**"(សូមមើលនិយមន័យ "**ទីផ្សារ**" នៅក្នុងអត្ថបទ "បញ្ហា និង ដំណោះស្រាយ ទីផ្សារបន្លែនៅកម្ពុជា" ដែលបានចុះផ្សាយក្នុងអត្ថបទស្រាវជ្រាវរបស់មន្ត្រីវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា ក្នុងខែកុម្ភៈ ឆ្នាំ២០១៩)។

តើអ្នកណាដែលត្រូវបំពេញតួនាទីជា "**ទីផ្សារ?**" គឺ **អាជ្ញាធរពាក់ព័ន្ធ**។

ទីផ្សារ គឺជាយន្តការ ដែលធ្វើឱ្យអ្នកលក់និងអ្នកទិញជួបគ្នា។ ដូច្នេះយើងលើកជា ឧទាហរណ៍ ក្នុងកម្រិតថ្នាក់ខេត្ត គឺមាន ខុទ្ទការល័យសាលាខេត្ត ជាសេនាធិការ និងមន្ទីរពាក់ព័ន្ធ ដូចជា មន្ទីរកសិកម្ម និងមន្ទីរទេសចរណ៍។ មន្ទីរកសិកម្ម គឺជាភាគីផលិតករឬផ្គត់ផ្គង់(តំណាងកសិករដាំបន្លែ)និងមន្ទីរទេសចរណ៍ គឺជាភាគីអ្នកប្រើប្រាស់ឬតម្រូវការ(តំណាងភោជនីយដ្ឋាន សណ្ឋាគារ)ដែលប្រើប្រាស់បន្លែ។

### តើភ្នាក់ងារនីមួយៗត្រូវបំពេញតួនាទីអ្វីខ្លះ?

**មន្ទីរកសិកម្ម** គឺជាភាគីផលិតករ ឬ ភាគីផ្គត់ផ្គង់(តំណាងកសិករដាំបន្លែ)ដែលជាអង្គភាពគ្រប់គ្រងទិន្នន័យ ប្រជាកសិករ សហគមន៍កសិករ យល់ដឹងអំពីសក្តានុពលផលិតកម្មតាមប្រភេទភូមិសាស្ត្រនិងប្រភេទផលិត កំណត់និងបែងចែកឯកទេសនីយកម្មនិងឧត្តមភាពប្រៀបធៀប តាមធនធានមនុស្សនិងធនធានភូមិសាស្ត្រ ពោលសមត្ថកិច្ចនេះ គឺដឹងព័ត៌មានអំពី អ្នកដែលអាចផលិតអ្វីបានច្រើនជាង និងកន្លែងដែលផលិតអ្វីបានទិន្នផលខ្ពស់ជាង ហើយកំណត់លទ្ធភាពបរិមាណផលិកម្ម។

**មន្ទីរទេសចរណ៍** គឺជាភាគីអ្នកប្រើប្រាស់ ឬ ភាគីមានតម្រូវការ ដែលជាអង្គភាពគ្រប់គ្រងទិន្នន័យអំពីភោជនីយដ្ឋាន សណ្ឋាគារ និងកន្លែងទេសចរណ៍ សំខាន់ៗនៅក្នុងមូលដ្ឋានរបស់ខ្លួន។ តាមរយៈនេះអាចដឹងអំពី បរិមាណ ប្រភេទបន្លែ ។ល។ ដែលចាំបាច់សម្រាប់បម្រើអតិថិជនរបស់ខ្លួនប្រចាំថ្ងៃ។

សរុបសេចក្តីមក មន្ទីរកសិកម្មជាផលិតករ ឬ ភាគីផ្គត់ផ្គង់បន្លែ ចំណែកឯ មន្ទីរទេសចរណ៍ ជាភាគីអ្នកប្រើប្រាស់ ឬ ភាគីតម្រូវការបន្លែ។ ដោយសេដ្ឋកិច្ចទីផ្សារសេរី ដូច្នេះអ្នកប្រើប្រាស់ ឬ អ្នកមានតម្រូវការគឺជាអធិរាជ ដូច្នេះមន្ទីរកសិកម្ម ត្រូវផ្គត់ផ្គង់អ្វីតាមការចង់បានរបស់ភាគីមន្ទីរទេសចរណ៍។

តើធ្វើបែបណាដើម្បីភាគីទាំងពីរជួបគ្នា? ឬធ្វើយ៉ាងណា ដើម្បីឱ្យភាគីតម្រូវការ និង ភាគីផ្គត់ផ្គង់ជួបគ្នា? ពោលគឺស្វែងរកទីផ្សារ?។

**ឧទ្ទការល័យសាលាខេត្ត** ជាសេនាធិការត្រូវដើរតួនាទីជា"**ទីផ្សារ**" ធ្វើឱ្យភាគីពាក់ព័ន្ធជួបគ្នា ដើម្បីចរចាអំពីលក្ខខណ្ឌ ដើម្បីឈានដល់ការចុះកិច្ចព្រមព្រៀងអំពីតម្រូវការ និងការផ្គត់ផ្គង់របស់ខ្លួន ហើយ ឧទ្ទការល័យសាលាខេត្ត ជាអ្នកជានាក្នុងការអនុវត្តកិច្ចព្រមព្រៀងរបស់ភាគីទាំងអស់។

ជាបន្តទៀត មន្ទីរពាក់ព័ន្ធទាំងពីរនេះ ត្រូវដើរតួជាអ្នកសម្របសម្រួល ឬ ចាត់ចែង ជាពិសេស **មន្ទីរកសិកម្ម** ត្រូវបែងចែក ទៅតាមឯកទេសធនធានមនុស្ស តាមភូមិសាស្ត្រ ។ល។ ដើម្បីឆ្លើយតបតាមចំណោទបញ្ហាគ្រឹះខាងលើ។ បែងចែកតាមជំនាញដើម្បីធ្វើឱ្យអ្នកផលិតឬអ្នកផ្គត់ផ្គង់(កសិករដាំបន្លែ)ជួបគ្នាដោយផ្ទាល់ ជាមួយ អ្នកប្រើប្រាស់ ឬអ្នកមានតម្រូវការ(ភោជនីយដ្ឋាន សណ្ឋាគារ) ដើម្បីចរចាអំពីលក្ខខណ្ឌ ដូចជា បរិមាណ ប្រភេទ តម្លៃ និង ពេលវេលាផ្គត់ផ្គង់ ជាដើម ដោយ ឧទ្ទការល័យសាលាខេត្ត និង មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអ្នកជានាក្នុងការអនុវត្តកិច្ចសន្យារបស់គ្រប់ភាគី។

**មន្ទីរសេដ្ឋកិច្ច** ជាអង្គភាពដែលក្រៅពីការផ្តល់ហិរញ្ញប្បទាន ការឧបត្ថម្ភធន ការផ្តល់ឥណទាន ។ល។ ជូនដល់កសិករ ក៏ត្រូវទទួលបន្ទុកជាអន្តរការីធានាការទូទាត់របស់ភាគីផ្គត់ផ្គង់ និង ភាគីតម្រូវការតាមលក្ខខណ្ឌ ដើម្បីជាទំនុកចិត្តដល់គ្រប់ភាគី។

**មន្ទីរពាណិជ្ជកម្ម** ជាអ្នកគ្រប់គ្រងការនាំចេញនិងនាំចូល( លើកយកតែករណីបន្លែ )អាចវិភាគអំពីបរិមាណនិងប្រភេទបន្លែដែលនាំចេញនិងនាំចូលឆ្លងកាត់ព្រំដែន ហើយអាចផ្តល់ព័ត៌មានដល់មន្ទីរកសិកម្ម ដើម្បីផ្សព្វផ្សាយដល់ផលិតករអំពីស្ថានភាពទីផ្សារបន្លែ ដើម្បីឆ្លើយតបទាន់ពេលវេលានូវចំណោទបញ្ហាជាគ្រឹះទាំងប្រាំគឺ៖ ១-តើគប្បីផលិតចំនួនប៉ុន្មាន? ២-តើរបស់អ្វីគប្បីផលិត? ៣- តើផលិផលនោះគប្បីផលិតបែបណា?, ៤-តើអ្នកណាទទួលផលិតផលនោះ? និង ៥- តើប្រព័ន្ធផលិតកម្មនេះអាចសម្របសម្រួលតាមតម្រូវការ ឬ ការផ្គត់ផ្គង់ធនធាន ក៏ដូចជា ការប្រែប្រួលបច្ចេកវិទ្យាដែរឬទេ? ទៅតាមស្ថានការណ៍ទីផ្សារ។

គប្បីកត់សម្គាល់ថា ជាមួយគ្នានឹងការលើកទឹកចិត្តដើម្បីមានកសិករដាំបន្លែកាន់តែច្រើន រដ្ឋាភិគប្បីគិតគូរអំពីឯកទេសនីយកម្មតាមភូមិសាស្ត្រ( Geographic Specialization )ផងដែរ ពោលត្រូវគិតគូរអំពីឧត្តមភាពប្រៀបធៀបតាមភូមិសាស្ត្រនីមួយៗ។ ឧទាហរណ៍នៅខេត្តតាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង មានសក្តានុពលក្នុងការដាំបន្លែយកស្លឹក ដូចជា ស្ពៃ ខាត់ណា សាឡាដ ត្រកួន ចំណែក ខេត្តកោះកុង មណ្ឌលគិរី រតនគិរី មានសក្តានុពលក្នុងការដាំដើមឈើហូបផ្លែ ដូចជា ល្ហុង ទៀបបារាំង ប៉ឺរ និងផ្លែ Passion ខេត្តព្រៃវែង ប៉ៃលិន បាត់ដំបង មានសក្តានុពលផ្នែកបន្លែពពួកគ្រឿងទេស ដូចជា រំដេង រមៀត ខ្ទឹម ខេត្តកំពង់ចាម តាកែវ សម្បូរកសិករចិញ្ចឹមសត្វយកសាច់ដូចជា ជ្រូក មាន់ ទា ការផលិតត្រីងៀត ត្រីឆ្អើរ សាច់ក្រក និង ខេត្តដែលសម្បូរស្រូវជាងគេ មានបាត់ដំបង តាកែវ កំពង់ស្ពឺ កំពតនិងព្រៃវែង

ជាដើម( សូមមើលៈ*http://www.lareine.com.kh/news/eco-bussiness/21348/*) ដើម្បីប្រើប្រាស់ធនធានសេដ្ឋកិច្ចដែលមាន ប្រកបដោយប្រសិទ្ធភាព។

## សន្និដ្ឋាន

ថ្វីបើនាពេលបច្ចុប្បន្ននេះ ទីផ្សារបន្លែនៅកម្ពុជា ត្រូវបានបំពេញដោយការនាំចូលពីប្រទេសជិតខាង លើស៥០ភាគរយនៃតម្រូវការក្នុងស្រុកក៏ដោយក្តី ប៉ុន្តែប្រទេសកម្ពុជានៅមានសក្តានុពលជាច្រើនទៀតដែលអាចបង្កើនការផ្គត់ផ្គង់បន្លែក្នុងស្រុក សម្រាប់ផ្គត់ផ្គង់តម្រូវការរបស់ខ្លួន ហើយថែមទាំងអាចកែច្នៃ ខ្ចប់វេច ដើម្បីនាំចេញទៅក្រៅប្រទេសថែមទៀត។

ដើម្បីសម្រេចបានពីប្រទេសដែលនាំបន្លែចូល ទៅជា ប្រទេសនាំបន្លែចេញនាពេលខាងមុខ គឺតម្រូវឱ្យរដ្ឋាភិបាលចូលរួមយ៉ាងសកម្ម ជាពិសេសរដ្ឋាភិបាលត្រូវលើកទឹកចិត្តដល់កសិករឱ្យដាំបន្លែកាន់តែច្រើន តាមរយៈ ឧបត្ថម្ភធន ជំនួយបច្ចេកទេស អន្តរាគមន៍ស្វែងរកទីផ្សារសម្រាប់ផលិតករ ជាអន្តរការី និងជាអ្នកធានារក្សាបរិមាណ គុណភាព ថ្លៃ និងការគោរពតាមកិច្ចសន្យាសម្រាប់គ្រប់ភាគីពាក់ព័ន្ធ ដើម្បីប្រជាកសិករមានទំនុកចិត្ត និងជំនឿក្នុងការជំរុញការដាំដុះបន្លែសម្រាប់ផ្គត់ផ្គង់ទីផ្សារក្នុងស្រុក និង អាចលើសតម្រូវការនាំចេញទៅក្រៅប្រទេស៕

## ឯកសារយោង


១. *http://kleykley.sabay.com.kh/article/1013701 )*។

២.*https://www.dap-news.com /2018/07/04/*)។

៣. *http://www.lareine.com.kh/news/eco-bussiness/21348/ )*